

# មែកធាងគ្រួសារ

## Family Tree


Written by TukTuk

Illustrated by Hen Choven



អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C



សួស្ដី! ខ្ញុំឈ្មោះរតនា។

ខ្ញុំគឺជាចៅស្រី កូនស្រី បងប្អូនស្រី ក្មួយស្រីនិងបងប្អូនជីដូនមួយម្នាក់ផងដែរ។ មនុស្សម្នាក់សោះ បែរជាមានតួនាទីយ៉ាងច្រើន។

តើមកពីហេតុអ្វីទៅ?



នេះគឺជាមករា។

គាត់គឺជាចៅប្រុស កូនប្រុស បងប្អូនប្រុស ក្មួយប្រុសនិងបងប្អូនជីដូនមួយម្នាក់ផងដែរ។ តើហេតុអ្វីទៅ?

ចាំខ្ញុំរៀបរាប់ប្រាប់អ្នកទាំងអស់គ្នា!



នេះគឺជាលោកតាលោកយាយរបស់ខ្ញុំ។ ខាងឆ្វេងគឺជាឪពុកម្ដាយរបស់ម្ដាយខ្ញុំ។
រីឯខាងស្ដាំគឺជាឪពុកម្ដាយរបស់ឪពុកខ្ញុំ។ មករាគឺជាចៅប្រុសរបស់ពួកគាត់។
ឯខ្ញុំវិញក៏ជាចៅស្រីរបស់ពួកគាត់ដែរ។



នេះគឺជាម្ដាយរបស់ខ្ញុំ។

គាត់ក៏ជាកូនស្រីម្នាក់ដូចខ្ញុំអីចឹងដែរ ព្រោះគាត់ជាកូនស្រីរបស់លោកតាលោកយាយខ្ញុំ។



នេះគឺជាឪពុករបស់ខ្ញុំ។

គាត់ក៏ជាកូនប្រុសម្នាក់ដូចមករាអ៊ីចឹងដែរ ព្រោះគាត់ជាកូនប្រុសរបស់លោកតាលោកយាយខ្ញុំ។



នេះគឺដាដាវិន។

គាត់ជាកូនស្រីរបស់លោកតាលោកយាយខ្ញុំ ហើយក៏ជាមីងរបស់ខ្ញុំផងដែរ។

គាត់និងឪពុកខ្ញុំជាបងប្អូនបង្កើតនឹងគ្នា ដូចខ្ញុំនិងមករាអ៊ីចឹង។



មករានិងខ្ញុំជាក្មួយប្រុសក្មួយស្រីរបស់គាត់។

គាត់បានរៀបការជាមួយវិច្ឆិកា ដូច្នេះវិច្ឆិកាក្លាយជាពូសាច់ថ្លៃរបស់ពួកខ្ញុំ។



នេះគឺដាដាវិន។

គាត់ជាកូនស្រីរបស់លោកតាលោកយាយខ្ញុំ ហើយក៏ជាមីងរបស់ខ្ញុំផងដែរ។

គាត់និងឪពុកខ្ញុំជាបងប្អូនបង្កើតនឹងគ្នា ដូចខ្ញុំនិងមករាអ៊ីចឹង។



មករានិងខ្ញុំជាក្មួយប្រុសក្មួយស្រីរបស់គាត់។
គាត់បានរៀបការជាមួយវិច្ឆិកា ដូច្នេះវិច្ឆិកាក្លាយជាពូសាច់ថ្លៃរបស់ពួកខ្ញុំ។



មករានិងខ្ញុំគឺជាចៅប្រុសចៅស្រីរបស់លោកតាលោកយាយ។ ពួកខ្ញុំក៏ជាក្មួយប្រុសក្មួយស្រីរបស់អ៊ំប្រុសអ៊ំស្រីនិងពូមីង ព្រមទាំងជាកូនប្រុសកូនស្រីរបស់ឪពុកម្ដាយពួកខ្ញុំផងដែរ។



នេះគឺជាស៊ីថា។

គាត់ជាក្មួយប្រុសឪពុកម្ដាយខ្ញុំ ត្រូវជាបងប្អូនជីដូនមួយខាងឪពុករបស់ខ្ញុំ។

គាត់ជាកូនប្រុសរបស់មីង ហើយក៏ត្រូវជាចៅប្រុសរបស់លោកតាលោកយាយខ្ញុំផងដែរ។




នេះគ្រាន់តែរៀបរាប់បីជំនាន់នៃគ្រួសារខ្ញុំតែប៉ុណ្ណោះ។ លោកតាលោកយាយជាជំនាន់ទីមួយនៅក្នុងតារាងពង្សាវតារនេះ។
ឪពុកម្តាយ អ៊ំប្រុសអ៊ំស្រីនិងពូមីងរបស់ខ្ញុំជាជំនាន់ទីពីរ។ រីឯខ្ញុំ មករានិងបងប្អូនជីដូនមួយរបស់ពួកខ្ញុំជាជំនាន់ទីបី។



ពេលដែលខ្ញុំធំឡើង ហើយមានកូន ពួកគេនឹងក្លាយជាជំនាន់ថ្មី។ ខ្ញុំនឹងក្លាយជាម្តាយម្នាក់។
មកានឹងក្លាយជាពូ ហើយឪពុកម្តាយខ្ញុំនឹងក្លាយជាលោកតាលោកយាយវិញម្តង។





អ្នកខ្លះអាចតាមដានពង្សាវតាររបស់គាត់បានជាច្រើនជំនាន់។
អ្នកខ្លះក៏រកឃើញថា គាត់ជាប់សាច់ឈាមជាមួយនឹងបុគ្គលល្បីល្បាញ។







អ្នកខ្លះទៀតក៏រកឃើញថា គ្រួសារគាត់មានពូជអម្បូរមកពីប្រទេសផ្សេងៗផងដែរ។
ចុះគ្រួសាររបស់អ្នកវិញ?

អង្គការរ៉ឺម៉កកង់បី
សម្រាប់កុមារ R4C

អង្គការរ៉ឺម៉កកង់បីសម្រាប់កុមារ(R4C)គឺជាអង្គការដែលមិនរកប្រាក់ចំណេញ និងផ្តោតលើការអប់រំកុមារតូចក្នុងប្រទេសកម្ពុជា។

អង្គការR4Cកំពុងដំណើរការគម្រោងកម្មវិធីបណ្ណាល័យចល័តតាមប្រព័ន្ធអនឡាញ ដែលមាននិន្នាការទៅលើសាលាមត្តេយ្យរដ្ឋ និងមត្តេយ្យសហគមន៍។

អង្គការR4Cបានចូលរួមអភិវឌ្ឍន៍ធនធានដ៏សមស្របទៅនឹងកម្មវិធីសិក្សារបស់ក្រសួង និងមានវគ្គបំប៉នលោកគ្រូ អ្នកគ្រូ។
សូមចូលទៅកាន់គេហទំព័រដើម្បីទទួលបានធនធានបង្រៀន៖ https://rermork.org/

ទទួលបានព័ត៌មានបន្ថែម

TUKTUK

Rotary

មូលនិធិផ្តល់ដោយអង្គការTukTuk និងអង្គការរ៉ូតារីក្លឹប។

សៀវភៅរឿងនេះគឺនិពន្ធដោយ Robert McCurdy និងRoberta Dahl ជាអ្នកស្ម័គ្រចិត្ត ដោយក្តីមេត្តាធម៌។ ពួកយើងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អ្នកស្ម័គ្រចិត្ត និងបុគ្គលិកទាំងអស់នៅក្នុងអង្គការជាមួយនឹង Sally Heinrich ដែលបានចូលរួមកែសម្រួល និងបកប្រែសៀវភៅរឿងនេះ។

ទទួលបានគំនូរជីវចល

ទទួលបានធនធានបង្រៀន